ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ ០១៧/សសណ ២០២៣

ថ្ងៃ សុក្រ ១៤ កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០២៣

## សេចក្តីជូនដំណឹង

## ស្តីពីការជ្រើសរើសនិស្សិត សិស្សទាំងពីរភេទ ប្រឡងចូលសិក្សាវគ្គនាយទាហានសកម្ម ជំនាន់ទី២៥ នាយទាហានទ័ពជើងគោកជំនាន់ទី១៣ នាយទាហានបន្តវេនជំនាន់ទី១៤ និងនាយទាហានជំនាញបច្ចេកទេសយោធា

**យោង** ប្រកាសលេខ ០៩១-០៩២-០៩៣ ប្រក.កពជ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២ របស់ក្រសួងការពារជាតិ ស្តីពីការជ្រើសរើស និងហ្វឹកហ្វឺននាយទាហានសកម្មជំនាន់ទី២៥ នាយទាហានទ័ពជើងគោកជំនាន់ទី១៣ នាយទាហានបន្តវេនជំនាន់ទី១៤

- ប្រកាសលេខ ០៩៥ ប្រក.កពជ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២ របស់ក្រសួងការពារជាតិ ស្តីពីការជ្រើសរើសនិស្សិត សិស្សមកបណ្តុះបណ្តាលជំនាញបច្ចេកទេសយោធា នៅវិទ្យាស្ថានបច្ចេកទេសយោធាតេជោ ហ៊ុន សែន។

គណៈកម្មការជ្រើសរើស និងត្រួតពិនិត្យលក្ខណសម្បត្តិសិក្ខាកាមមកបណ្តុះបណ្តាលនៅក្នុង និងក្រៅប្រទេស សូមជូនដំណឹងដល់បេក្ខជននិស្សិត សិស្សទាំងពីរភេទ ដែលស្ម័គ្រចិត្តចូលបម្រើការងារក្នុងក្របខ័ណ្ឌ នៃកងយោធពលខេមរភូមិន្ទ ត្រូវមកទំនាក់ទំនងនិងសុំដាក់ពាក្យចុះឈ្មោះចូលប្រឡងជ្រើសរើសវគ្គនាយទាហាន តាមប្រកាសលេខ ០៩១-០៩២-០៩៣ និង០៩៥ របស់ក្រសួងការពារជាតិ ដូចមានលក្ខខណ្ឌជ្រើសរើស ទីកន្លែងនិងកាលបរិច្ឆេទដូចខាងក្រោម៖

**ក.លក្ខខណ្ឌជ្រើសរើស**

១.សញ្ជាតិខ្មែរ

២.មានអាយុពី១៨ឆ្នាំ ដល់២៥ឆ្នាំ គិតត្រឹមថ្ងៃដាក់ពាក្យសុំចុះឈ្មោះចូលប្រឡង

៣.មានកាយសម្បទាគ្រប់គ្រាន់តាមតម្រូវការ ដើម្បីបំពេញមុខងារ

៤.មិនធ្លាប់ត្រូវបានតុលាការផ្តន្ទាទោស

៥.មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

៦.បុរសមានកម្ពស់ ១៦០ស.ម និងនារីមានកម្ពស់ ១៥០ស.ម ឡើងទៅ

**ខ.ទីកន្លែង និងកាលបរិច្ឆេទ**

- ការចែកពាក្យនិងទទួលពាក្យសុំចុះឈ្មោះចូលប្រឡងនឹងត្រូវចាប់ផ្តើមពីថ្ងៃទី០១ ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣
- ទីកន្លែងចែកពាក្យ និងទទួលពាក្យ នៅសាកលវិទ្យាល័យការពារជាតិ

អាសយដ្ឋានទំនាក់ទំនងតាមរយៈ វិបសាយ អ៊ីម៉ែល ទូរស័ព្ទលេខ៖

- **វិបសាយ** WWW : cot.mod.gov.kh (Facebook): RCAF Cambodia
- **អ៊ីម៉ែល** Email : cotcambodia@mod.gov.kh
- **ទូរស័ព្ទលេខ ០១២ ៨៦ ៧៧ ៥៨ / ០៩៧ ៧៣ ០០ ៤១១ / ០៩៧ ៥៧ ៧៧ ៧៥៧**

បេក្ខជននិស្សិត សិស្សទាំងពីរភេទត្រូវមកទំនាក់ទំនងសាកសួរព័ត៌មានលម្អិត និងបំពេញទម្រង់បែបបទផ្សេងៗ នៅទីកន្លែងទទួលពាក្យនិងដាក់ពាក្យ នៅរៀងរាល់ម៉ោងធ្វើការ ។

**រដ្ឋលេខាធិការ ក្រសួងការពារជាតិ**

**និងជាប្រធានគណៈកម្មការ**

នាយឧត្តមសេនីយ៍.គួច_ស៊ីផាន